**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថានឯកអគ្គរាជទូតកម្ពុជា**
**ប្រចាំប្រទេសជប៉ុន**

**សូមគោរពជូន**
**ឯកឧត្តម ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ:** របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ចជប៉ុន ក្នុងខែ កញ្ញា ឆ្នាំ ២០១២ ។

ខ្ញុំបាទមានកិត្តិយសសូមរាយការណ៍ជូន **ឯកឧត្តម** មេត្តាជ្រាបថា កាលពីរសៀលថ្ងៃទី ២៦ ខែ កញ្ញាឆ្នាំ ២០១២ នៅការិយាល័យខុទ្ទកាល័យរដ្ឋាភិបាលជប៉ុន មានរៀបចំកិច្ចប្រជុំមួយទាក់ទង ស្ថានភាពសេដ្ឋកិច្ចជប៉ុន នាពេលបច្ចុប្បន្ន ។

ខាងក្រោមនេះជាចំណុចសំខាន់ៗនៃការវាយតម្លៃសភាពការណ៍សេដ្ឋកិច្ច:

**១**-ផលិតកម្មឧស្សាហកម្មកំពុងងើបឡើងយឺតៗ ដោយសារការលក់រថយន្ត ក្នុងប្រទេសជប៉ុន និងក្រៅប្រទេសបានធ្លាក់ចុះ ហើយការងើបឡើងវិញនៃសេដ្ឋកិច្ចបរទេសមានកំរិតខ្សោយដែរ ។

**២**-កម្រៃរបស់ក្រុមហ៊ុនបានកើនឡើង ហើយការវិនិយោគពាណិជ្ជកម្មមានកំណើនដោយសារតម្រូវការក្រោយគ្រោះធម្មជាតិ នាឆ្នាំ ២០១១ កន្លងមក ។

**៣**-ការវាយតម្លៃរបស់សហគ្រាសលើលក្ខណ្ឌអាជីវកម្មបច្ចុប្បន្នបានបង្ហាញឱ្យឃើញថា មានភាពប្រសើរតិចតួច ចំពោះសហគ្រាសទូរទៅ កំពុងពិនិត្យស្ថានការណ៍យ៉ាងប្រុងប្រយ័ត្នអំពីអនាគតដ៏ខ្លីខាងមុខ ។

**៤**-បញ្ហាការងារនៅជាបញ្ហាស្រួចស្រាវនៅឡើយ កត្តាបណ្តាលមកពីគ្រោះធម្មជាតិ ហើយអ្នកគ្មានការងារធ្វើស្មើនឹង ៤.៣% ឬ ២.៨៨ លាននាក់ កាលពីខែ កក្កដា ឆ្នាំ ២០១២ គឺថយចុះ ២៤០,០០០ នាក់ ស្មើនឹង ៧.៧%ខុសពីឆ្នាំមុន ។ រីឯ ចំនួនអ្នកមានការងារធ្វើវិញមានចំនួន ៦២.៧៧ លាននាក់ ហើយថយចុះ ៥០. ០០០ នាក់ ឬស្មើនឹង ០.១% ខុសពី ឆ្នាំមុន ។

**៥**-អត្រាកំណើនផលទុនជាតិសរុបប្រចាំឆ្នាំ ២០១០ មានចំនួន ៣.១% ប្រចាំឆ្នាំ ២០១១ បានធ្លាក់ចុះ -០.១% និងការព្យាករណ៍ឆ្នាំ ២០១២ មាន ២.០% ។ សំរាប់ឆ្នាំ សារពើពន្ធ ២០១២ សេដ្ឋកិច្ចជប៉ុនសង្ឃឹមថានឹងកើនឡើង ដោយសារកំណើនតម្រូវការក្នុងស្រុក ជាអាទិ៍ ការអនុវត្តនីយ៉ាងពេញទំហឹងនូវវិធានការកសាងឡើងវិញនៅតំបន់ខូចខាត ហើយរំពឹងថា នឹងបង្កើតតម្រូវការ ជាពិសេសការងារ ។

**៦**-តម្លៃទំនិញនៅទូទាំងប្រទេស ក្នុងខែ កក្កដា ឆ្នាំ ២០១២ មានលំនឹង ឬប្រចាំឆ្នាំកើនចំនួន ០.១% ។

**៧**-ជារួមការនាំចេញមានសន្ទុះខ្សោយ ហើយការនាំចូលមានលំនឹង ។ ការនាំចេញទៅប្រទេសអា

8-6-9 AKASAKA, MINATO-KU, TOKYO 107-0052 Tel: (81 3)5412-8521 Fax: (81 3)5412-8526
E-mail : camembassyjp@gmail.com

ស៊ីមានិកវិតទាប ការនាំចេញទៅអាមេរិកមានលំនឹង និងទៅអឺរ៉ុបថយចុះ ។ ចំណែកឯការនាំ ចូលពីបណ្ដាប្រទេសអាស៊ី និងអឺរ៉ុប មានលំនឹង ពីអាមេរិកកំពុងកើនឡើង ។

**៨-ពាណិជ្ជកម្មទ្វេភាគី កម្ពុជា-ជប៉ុន**

-ទឹកប្រាក់ពាណិជ្ជកម្មសរុបពីខែ មករា-កក្កដាឆ្នាំ ២០១២ ក្នុងការនាំចេញទំនិញ ពីកម្ពុជាមកជប៉ុនមាន ចំនួន ១៧, ២៧១, ៩៣៥,000 យ៉េន ។ តួរលេខកើនឡើងខែដូចគ្នាលើសឆ្នាំ ២០១១ ចំនួន ៣១ % ។

-ទឹកប្រាក់ពាណិជ្ជកម្មសរុប ពីខែ មករា-កក្កដា ឆ្នាំ ២០១២ ក្នុងការនាំចេញទំនិញ ពីជប៉ុនទៅប្រទេសកម្ពុជា មាន ចំនួន ១០, ០១៥, ២៣១, 000 យ៉េន ។ តួរលេខកើនឡើងខែដូចគ្នាលើសឆ្នាំ ២០១១ ចំនួន ៦% ។

តាមរយៈនៃការអភិវឌ្ឍន៍ចុងក្រោយនេះ បានបង្ហាញឱ្យឃើញថាសេដ្ឋកិច្ចជប៉ុនកំពុងស្ថិតនៅក្នុងបរិត្តណាកវិតស្រាល ។ កត្តាដែលធ្វើឱ្យសេដ្ឋកិច្ចជាតិចុះថយ បណ្ដាលមកពី ការធ្លាក់ចុះថយនៃសេដ្ឋកិច្ចសាកលលោកក្នុងនោះរាប់បញ្ចូលវិបត្តិបំណុលដ៏ធ្ងន់នៅតំបន់អឺរ៉ូ ប្រាក់យ៉េនឡើងថ្លៃ ការរើទីតាំងរោងចក្រផលិតចេញពីជប៉ុនទៅក្រៅប្រទេស កង្វះខាតការផ្គត់ផ្គង់អគ្គិសនី និងតម្លៃខ្ពស់នៃប្រេឥន្ធនៈ ។

រដ្ឋាភិបាលនឹងខិតខំអនុវត្តទីវាល់មធ្យោបាយបញ្ជៀសកំណើនយឺតៗនៃសេដ្ឋកិច្ច បន្ថែមទៀត នឹងធ្វើការស្តារឡើងវិញនៅតំបន់រងគ្រោះ និងសំរេចយកជ័យជំនះលើបរិត្តផរណា និងការពារកុំឱ្យសេដ្ឋកិច្ច ធ្លាក់ចូលក្នុងការកើតមានឡើងដដែលៗនៃប្រាក់យ៉េនឡើងថ្លៃ និងបរិត្តផរណា ។

អាស្រ័យហេតុនេះសូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ ។

សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

តូក្យូ ថ្ងៃ ទី ២៦ ខែ កញ្ញា ឆ្នាំ ២០១២

លឹម ធារិទ្ធ